FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ



ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ការចិញ្ចឹមត្រីក្នុងស្រែ

ត្រីជាប្រភពប្រូតេអ៊ីនដ៏សំខាន់សម្រាប់សរីរាង្គសត្វ និងមនុស្ស លើសពីនេះទៅទៀត វាជាប្រភេទសាច់ដែលពុំផ្តល់ទុក្ខទោសដល់សុខភាព។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋកម្ពុជាភាគច្រើន និយមចូលចិត្តបរិភោគសាច់ត្រីជាអាហារ តាមការស្ទាបស្ទង់របស់អង្គការក្រៅរដ្ឋាភិបាលមួយបានឲ្យដឹងថា ប្រមាណ ៦០ភាគរយ នៃអាហារជាតិសាច់ដែលប្រជាពលរដ្ឋបរិភោគប្រចាំថ្ងៃ គឺជាសាច់ត្រី។

បច្ចុប្បន្ននេះបរិមាណផលត្រីក្នុងធម្មជាតិមានការថយចុះជាលំដាប់ ទន្ទឹមនឹងនេះកំណើនប្រជាជនកាន់តែកើនឡើង។ បុព្វហេតុនេះ ការចិញ្ចឹមត្រីក្នុងស្រែគួបផ្សំដំណាំស្រូវ មិនត្រឹមតែទទួលបាននូវអង្ករ និងសាច់ត្រីសម្រាប់ការហូបចុកប្រចាំថ្ងៃប៉ុណ្ណោះទេ វាក៏បានរួមចំណែកក្នុងការកាត់បន្ថយការចាប់ត្រីពីផលស្តុកធម្មជាតិផងដែរ។




## ១. សារៈសំខាន់នៃការចិញ្ចឹមត្រីក្នុងស្រែ

- កាត់បន្ថយការចំណាយទៅលើការទិញម្ហូបប្រចាំថ្ងៃ
- ការចិញ្ចឹមត្រីក្នុងស្រែអាចជួយបង្កើនគុណភាពដី អាចឲ្យទិន្នផលស្រូវកើនឡើង
- រួមចំណែកកាត់បន្ថយការចាប់ត្រីពីធម្មជាតិ ជាកត្តាមួយជួយឲ្យបរិមាណត្រីក្នុងធម្មជាតិកើនឡើងវិញ
- ងាយស្រួលចាប់យកមកធ្វើម្ហូប ព្រោះស្រែចិញ្ចឹមត្រីនៅជិតផ្ទះស្រាប់

## ២. ការរៀបចំស្រែចិញ្ចឹមត្រី

### ការជីកជម្រក

ជម្រកគឺជាជង្ហុក ឬទីដែលជ្រៅជាងគេនៅក្នុងស្រែចិញ្ចឹមត្រី វាជាទីកន្លែងដែលត្រីរត់មកជ្រកពេលណាទឹកក្នុងស្រែរាក់ ឬក្តៅពេក។ គេអាចប្រើប្រាស់ជម្រកនេះសម្រាប់បង្ខាំងត្រីជាបណ្តោះអាសន្ន នៅពេលប្រើថ្នាំសម្លាប់សត្វល្អិតការពារដំណាំស្រូវផងដែរ។ ជម្រកដែលត្រូវជីកអាចមានរាងច្រើនសណ្ឋាន ទៅតាមភូមិសាស្ត្រនៃដីស្រែ



ស្រះជីកនៅតាមជ្រុងស្រែ

ឬទៅតាមចំណង់ចំណូលចិត្តរបស់អ្នកចិញ្ចឹម។ ជម្រកអាចមានរាងជា ប្រឡាយ ឬ ស្រះ។

### ជម្រកមានរាងជាប្រឡាយ

ជម្រកបែបនេះ គេអាចជីកប្រឡាយតូចៗតាមបណ្ដោយភ្លឺស្រែ ដែលមានជំរៅពី ៤០ ទៅ ៥០ សង់ទីម៉ែត្រ ហើយផ្ទៃក្រឡានៃប្រឡាយមានទំហំប្រមាណ ៥ ទៅ ១០ ភាគរយ នៃក្រឡាផ្ទៃស្រែសរុប។

### ជម្រកមានរាងជាស្រះ

នោះគឺជាប្រភេទជម្រកមួយបែប ដែលគេជីកមានសណ្ឋានជាស្រះតូចៗ។ គេអាចជីកស្រះ នៅកណ្ដាលស្រែ ឬជ្រុងស្រែក៏បាន ដោយមានជម្រៅ ១ ទៅ ១,៥ ម៉ែត្រ ប៉ុន្តែផ្ទៃក្រឡានៃស្រះ ក៏គួរតែមានប្រមាណពី ៥ ទៅ ១០ភាគរយ នៃផ្ទៃក្រឡាស្រែសរុបដែរ។

## ៣. ការជ្រើសរើសពូជត្រីមកចិញ្ចឹម



**ការរៀបចំស្រែចិញ្ចឹម**

ប្រភេទត្រីដែលអាចចិញ្ចឹមក្នុងស្រែបានមានជាអាទិ៍ដូចជា ត្រីកាបសាមញ្ញ ត្រីទីឡាព្យា ត្រីកាបឥណ្ឌា ត្រីកន្ធរ និងត្រីអណ្ដែង។ ការចិញ្ចឹមត្រីក្នុងស្រែជាទូទៅធ្វើនៅក្នុងស្រែជម្រៅ ជាកន្លែងដែលដក់ទឹកបានជ្រៅ។ ការចិញ្ចឹមត្រីកាបសាមញ្ញ ទីឡាព្យា និង កាបឥណ្ឌា អាចចិញ្ចឹមចម្រុះគ្នាតែម្ដងក្នុងស្រែតែមួយ ក្នុងកម្រិតសមាមាត្រ ត្រីកាបសាមញ្ញ ៥០% ត្រីទីឡាព្យា ៣០% និងត្រីកាបឥណ្ឌា ២០% ។ ការចិញ្ចឹមពុំចាំបាច់ផ្ដល់ចំណីអ្វីទាំងអស់ បើគេចិញ្ចឹមក្នុងដង់ស៊ីតេ ១ក្បាល ក្នុង៣-៤ ម៉ែត្រការ៉េ។ គេអាចចិញ្ចឹមក្នុងដង់ស៊ីតេរហូតដល់ ២ ក្បាលក្នុងមួយ ម៉ែត្រការ៉េ តែករណីនេះគេត្រូវតែផ្ដល់ចំណីបន្ថែមដូចជា កន្ទក់ ចកបាយទា កណ្ដៀរ ឬកាកសំណល់ផ្ទះបាយជាដើម។ ទំហំកូនត្រីដែលគួរជ្រើសរើសមកចិញ្ចឹម ត្រូវតែមានទំហំយ៉ាងតិច ប៉ុនម្រាមដៃឡើងទៅ និងមានសុខភាពល្អ ។ ដោយឡែកត្រីអណ្ដែង មានលក្ខណៈពិសេសជាងបណ្ដាត្រីដែល បានរៀបរាប់ខាងលើ ដោយគេអាចចិញ្ចឹមវាក្នុងល័ក្ខខ័ណ្ឌទឹករាក់ដែលមានជម្រៅត្រឹម ២០ សង្ទីម៉ែត្រប៉ុណ្ណោះ (ទឹកក្នុងស្រែ) ព្រោះវាជាប្រភេទត្រីដែលធន់ទៅនឹងបំរែបំរួលសីតុណ្ហភាព និងជំងឺផ្សេងៗបានល្អ ហើយការ ចិញ្ចឹមមានអត្រារស់ខ្ពស់ថែមទៀតផង។ តែការចិញ្ចឹមត្រីអណ្ដែង ចាំបាច់ត្រូវតែផ្ដល់នូវចំណីបន្ថែម ទោះជាការ ចិញ្ចឹមក្នុងដង់ស៊ីតេទាប ឬខ្ពស់ក៏ដោយ។

## ៤. ការជ្រើសរើសពូជស្រូវសម្រាប់ស្រែចិញ្ចឹមត្រី

អាស្រ័យដោយការចិញ្ចឹមត្រីអណ្ដែងមានរយៈពេលលើសពីបីខែ ដូច្នេះគួរជ្រើសរើសពូជស្រូវធ្ងន់ មកធ្វើការដាំដុះក្នុងការធ្វើវប្បកម្មចម្រុះនេះ។ ដោយឡែកត្រីកាប ឥណ្ឌា កាបសាមញ្ញ និងទីឡាព្យា អាចធ្វើវប្បកម្មជាមួយពូជស្រូវកណ្ដាលបាន។

## ៥. ការលែងកូនត្រីចិញ្ចឹម

ការដឹកជញ្ជូនកូនត្រីគួរធ្វើនៅពេលព្រឹក និងការលែងកូនត្រីចូលស្រែចិញ្ចឹម គួរធ្វើនៅចន្លោះម៉ោង ៩-១០ព្រឹក ។ បើកូនត្រីត្រូវបានដឹកជញ្ជូនដោយប្រើថង់ប្លាស្ទិក នោះពេលដឹកជញ្ជូនដល់ស្រែ ត្រូវយកថង់នោះទៅត្រាំក្នុងទឹកស្រែដែលត្រូវចិញ្ចឹមប្រមាណ ១០-១៥នាទីសិន រួចទើបស្រាយមាត់ថង់ឲ្យត្រីហែលចេញដោយខ្លួនឯងសន្សឹមៗ ចូលទៅក្នុងស្រែចិញ្ចឹមត្រី។

## ៦. ការផ្តល់ចំណី

ថ្វីត្បិតតែត្រីអណ្តែងជាប្រភេទត្រីស៊ីសាច់ជាអាហារ តែក្នុងការចិញ្ចឹមយើងអាចយកកន្ទក់មកលាយនឹងសាច់បាន។ ឆ្លងតាមការពិសោធន៍នៅក្នុងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានចេញជាលទ្ធផលថា ត្រីដែលចិញ្ចឹមដោយផ្តល់ចំណីកន្ទក់ ២០% លាយត្រីហាល ៨០% មានការធំធាត់រហ័ស និងអត្រារស់ច្រើនជាងត្រីដែលផ្តល់ដោយចំណីកន្ទក់ ៦០% លាយត្រីហាល ៤០% ឬក៏កន្ទក់ ៤០% លាយត្រីហាល ៦០%។ ពេលផ្តល់ចំណីត្រូវដាក់ក្នុងកញ្ច្រែងក្រាលស្បៃរួចជ្រមុជទៅក្នុងទឹក ដើម្បីងាយស្រួលតាមដានមើលការស៊ីចំណីរបស់ត្រី និងជៀសវាងភាពខ្ជះខ្ជាយ។ ការផ្តល់ចំណីនេះអាចផ្តល់នៅពេលព្រឹក ចាប់ពីម៉ោង ៩ ដល់ម៉ោង ១០ និង ល្ងាចចន្លោះពីម៉ោង ៣ ទៅ ម៉ោង ៥ ដោយផ្តល់មួយថ្ងៃម្តង ឬពីរដង ក៏បានតាមកំរិតប្រមាណ ១០% នៃទម្ងន់ដងខ្លួនត្រីសរុប (ឧបមាថាទម្ងន់កូនត្រីសរុបក្នុងស្រែមានប្រមាណ ១០ គីឡូក្រាម នោះចំណីដែលត្រូវផ្តល់គឺ ១ គីឡូក្រាមក្នុងមួយថ្ងៃ ឬ ព្រឹក កន្លះគីឡូក្រាម ល្ងាចកន្លះគីឡូក្រាម)។

## ៧. ការប្រមូលផល

ការប្រមូលផលអាចចាប់រំលោះ ដោយចាប់ត្រីណាដែលធំជាងគេមកធ្វើម្ហូបប្រចាំថ្ងៃ។ ការប្រមូលផលសរុបធ្វើឡើងនៅពេលស្រូវទុំល្អ ពេលនោះត្រីនៅប្រមូលផ្តុំគ្នាក្នុងជម្រក (ប្រឡាយ ឬស្រះតូច) ។ ការប្រមូលផលនេះ ធ្វើដំណាលគ្នាជាមួយការច្រូតកាត់ផលស្រូវតែម្តង ប្រសិនបើទំហំត្រីធំល្មមអាចយកមកហូបឬលក់បាន ។ ប៉ុន្តែបើទំហំវាពុំទាន់សមស្របទេនោះ គេអាចបន្តការបង្ខាំងចិញ្ចឹមក្នុងជម្រក ដូចរៀបរាប់ខាងលើជាបណ្តោះអាសន្នសិន ពេលនោះគេអាចធ្វើការភ្ជួររាស់ ដកស្ទូងស្រូវជាលើកទីពីរទៀត (ករណីពូជស្រូវស្រាលមិនប្រកាន់រដូវ)។ ក្រោយពីស្ទូងបាន ១០ - ១៥ ថ្ងៃ គេអាចបើកលែងត្រីឲ្យចេញពីជម្រកចូលទៅក្នុងស្រែបាន។ ការចិញ្ចឹមក្នុងវគ្គទីពីរនេះ មានការផ្តល់ចំណី និងថែទាំដូចការចិញ្ចឹមក្នុងវគ្គទីមួយដែរ។

